ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អគ្គលេខាធិការដ្ឋាន
លេខ ០៤៤ គ.ជ.ប/អគ្គ/ប្រ.ក.៣

ថ្ងៃសុក្រ ៥រោច ខែស្រាពណ៌ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១៨

សេចក្តីប្រកាសព័ត៌មាន

គ.ជ.ប ស្នើយោបល់ពីភាគីពាក់ព័ន្ធលើសេចក្តីព្រាងបទបញ្ជា និងនីតិវិធី សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ

គិតត្រឹមថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានបញ្ជូនសំណើសុំពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ទៅឱ្យភាគីពាក់ព័ន្ធនានារួចរាល់ហើយ ដើម្បីធ្វើការពិនិត្យ និងពិចារណាកែតម្រូវមុននឹងដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។

ភាគីពាក់ព័ន្ធទាំងអស់រួមមាន ៖

- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រសួងការពារជាតិ
- ក្រសួងព័ត៌មាន
- គណបក្សនយោបាយ ចំនួន ២០
- ស្ថានទូត ជប៉ុន ប្រចាំនៅកម្ពុជា
- អង្គការមិនមែនរដ្ឋាភិបាលជាតិ និងសមាគម ចំនួន ២៤

ភាគីពាក់ព័ន្ធទាំងអស់ត្រូវបញ្ជូនការផ្តល់យោបល់លើសេចក្តីព្រាងបទបញ្ជា និងនីតិវិធីនេះ មក គ.ជ.ប វិញយ៉ាងយូរ ត្រឹមថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨ ។

សូមជម្រាបជូនថា សេចក្តីព្រាងបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ មាន ៧ ជំពូក និង៥ឧបសម្ព័ន្ធចំនួន ៥ ស្មើនឹង ២១០ ទំព័រ មានបង្ហោះនៅលើគេហទំព័រ គ.ជ.ប ដែលមានអាសយដ្ឋាន www.necelect.org.kh/khmer/content/3529 ៕

ទំនាក់ទំនង : 023 214 231 / 012 855 018 ; E-mail: necinfo@forum.org.kh ; www.necelect.org.kh

ឯកឧត្តម **ឆេង នីថា** បានស្នើសិក្ខាកាមទាំងអស់យកចិត្តទុកដាក់សិក្សា ដើម្បីបន្តបណ្តុះបណ្តាលតាមស្តាប់នរបស់ខ្លួន និងដើម្បីបន្តពង្រឹងកិច្ចសហការតាមតួនាទី ជំរុញឱ្យការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៨ ទទួលបានជោគជ័យ និងសូមណែនាំលោក លោកស្រីប្រធាន លធ.ខប ឱ្យយកចិត្តទុកដាក់លើការងារដូចខាងក្រោម ៖

- ត្រៀមអនុវត្តការងារជ្រើសរើសក្រុមចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ក្នុងរាជធានី ខេត្ត របស់ខ្លួន ដោយតម្លាភាព បើកចំហ ផ្អែកលើសមត្ថភាពជំនាញ បទពិសោធន៍ការងារ និងមិនត្រូវប្រកាន់និន្នាការនយោបាយណាមួយឡើយ ។
- បន្តរៀបចំវគ្គបណ្តុះបណ្តាលអំពីការងារពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតនៅថ្នាក់រាជធានី ខេត្ត និងនៅតាមមណ្ឌលប្រមូលផ្តុំក្រុង ស្រុក ខណ្ឌ ដោយត្រូវយកចិត្តដាក់ទុកបណ្តុះបណ្តាលឱ្យបានស៊ីជម្រៅ អំពីនីតិវិធីនៃការអនុវត្តការងារទាំងទ្រឹស្តី ទាំងបច្ចេកទេសកុំព្យូទ័រ ជូនដល់មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ជាពិសេសគ្រូបង្ហាត់ប្រចាំក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមចុះឈ្មោះបោះឆ្នោត ។
- តាមដាន និងសម្របសម្រួលដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ពិសេសការប្រើប្រាស់សម្ភារ ឯកសារ និងបរិក្ខារបម្រើឱ្យការចុះឈ្មោះបោះឆ្នោត និងត្រូវណែនាំគ្រូបង្ហាត់ប្រចាំក្រុង ស្រុក ខណ្ឌ ឱ្យចុះតាមដាន និងសម្របសម្រួលការងារឱ្យបានជាប្រចាំជាមួយក្រុមចុះឈ្មោះបោះឆ្នោត ទាក់ទងនឹងការអនុវត្តនីតិវិធីចុះឈ្មោះបោះឆ្នោត ការបញ្ចូល និងការបញ្ជូនទិន្នន័យតាមប្រព័ន្ធកុំព្យូទ័រ ។
- បន្តកិច្ចសហការឱ្យបានជិតស្និទ្ធជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដើម្បីសម្របសម្រួល និងចាត់វិធានការដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការងារចុះឈ្មោះបោះឆ្នោត ដែលកើតមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងត្រូវរាយការណ៍ជាប្រចាំ និងជាបន្ទាន់អំពីករណីដែលត្រូវស្នើសុំយោបល់ណែនាំ ឬស្នើសុំការដោះស្រាយពី គ.ជ.ប ។ ទន្ទឹមនេះ ត្រូវយកចិត្តទុកដាក់ស្នើសុំកិច្ចសហការពីអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកការងារសន្តិសុខ ដើម្បីពង្រឹងសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ ក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។

សូមជម្រាបជូនថា វគ្គបណ្តុះបណ្តាលនេះធ្វើឡើងរយៈពេល ៣ ថ្ងៃ ចាប់ពីថ្ងៃទី៣១ ខែសីហា ដល់ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៨ នៅសាលសន្និសីទ គ.ជ.ប អគារថ្មី ដោយមានអ្នកចូលរួមជាមន្ត្រី លធ.ខប តំណាងគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល សរុប ១៥០ នាក់ ៕